**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម

លេខ ១៤០១ ព.ណ.គ.ស.ពក

ថ្ងៃចន្ទ ១១កើតខែពិសាខ ឆ្នាំមមីរ អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែមេសា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅឱ្យបានជ្រាបថា មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ នៃសាធារណរដ្ឋកូរ៉េ នឹងរៀបចំពិព័រណ៌ «ASEAN Panorama» ពីថ្ងៃទី៤-៣០ ខែមិថុនា ឆ្នាំ២០២៦ នៅASEAN Hall, Press Center សាធារណរដ្ឋកូរ៉េ។ ព្រឹត្តិការណ៍ពិព័រណ៌នេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីផលិតផលរបស់ប្រទេសដែលជាសមាជិកអាស៊ាន ពាក់ព័ន្ធនឹងអាហារនិងភេសជ្ជៈ សេវាកម្មឌីជីថល និងទំនិញប្រើប្រាស់ទូទៅដល់អ្នកប្រើប្រាស់ និងក្រុមហ៊ុនកូរ៉េ តាមរយៈការដាក់តាំងបង្ហាញផលិតផលរយៈពេល ២៦ថ្ងៃ ដោយគណៈកម្មការរៀបចំពិព័រណ៌នឹងទទួលបន្ទុកលើការដឹកជញ្ជូនផលិតផលដែលត្រូវយកទៅដាក់តាំងបង្ហាញ។ សម្រាប់ក្រុមហ៊ុនដែលចូលរួមដាក់តាំងបង្ហាញផលិតផល នឹងត្រូវបានអញ្ជើញចូលរួមសិក្ខាសាលា និងជំនួបពាណិជ្ជកម្មពីថ្ងៃទី២២-២៥ ខែមិថុនា ឆ្នាំ២០២៦ នៅសាធារណរដ្ឋកូរ៉េផងដែរ ដោយគណៈកម្មការរៀបចំនឹងផ្តល់ជូននូវការស្នាក់នៅសម្រាប់អ្នកចូលរួម ១រូប/ក្រុមហ៊ុន។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ជាពាណិជ្ជករ និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកបំពេញបែបបទចូលរួម តាមរយៈនាយកដ្ឋានជំរុញពាណិជ្ជកម្ម និងកិច្ចការពិព័រណ៌ អគ្គនាយកដ្ឋានគោលនយោបាយ និងជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ដែលមានអាសយដ្ឋានឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួល តាមរយៈទូរស័ព្ទលេខ +៨៥៥ ៨៦ ៣៣៣ ៩៣៣ / +៨៥៥ ៧៧ ៣៦១ ៨៣៦ ឬអ៊ីមែល sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦៕

សម្រាប់ចុះឈ្មោះ

https://go.gov.kh/moc/md1j48
GO.gov.KH

សូមអរគុណ!

**KINGDOM OF CAMBODIA**

**Nation - Religion - King**

**Ministry of Commerce**

N°1401.MOC.D/TPEA

Phnom Penh, 27 April 2026

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honour to inform traders and the general public that the ASEAN-Korea Center ( AKC ) will organize the "ASEAN Panorama" exhibition from 4 to 30 June 2026 at the ASEAN Hall, Press Center, Republic of Korea.

This 26-day exhibition will showcase a wide range of ASEAN products to Korean consumers and businesses, particularly in the sectors of food and beverages, digital services, and consumer goods. The organizers will facilitate the shipment of exhibition items. Participating companies will also have the opportunity to attend seminars and business meetings scheduled from 22 to 25 June 2026 in the Republic of Korea. Accommodation will be provided for one representative from each exhibiting company.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite all Cambodian traders and the public who are interested in the aforementioned event to kindly register with the Department of Trade Promotion and Exhibition Affairs, General Department of Trade Policy and Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or officials in charge via:

Tel: +855 86 333 933 / +855 77 361 836

MOC Call Center: 1266

E-mail: sorn.pitou@moc.gov.kh / oun.veasna@moc.gov.kh

THANK YOU!

For Registration

https://go.gov.kh/moc/md1j48

GO.gov.KH